អ្វីដែលត្រូវយល់ដឹងអំពីមេរោគអេដស៍ (HIV)

តើអ្វីទៅជាមេរោគអេដស៍?

មេរោគដែលធ្វើឱ្យចុះខ្សោយប្រព័ន្ធភាពស៊ាំរបស់មនុស្ស (Human Immunodeficiency Virus, HIV) វាយប្រហារលើប្រព័ន្ធការពារាងកាយ។ ប្រសិនបើមិនបានព្យាបាលទេ វាអាចនាំឱ្យកើតជំងឺអេដស៍ (Acquired Immune Deficiency Syndrome, AIDS)។

តើមេរោគអេដស៍រីករាលដាលយ៉ាងដូចម្តេច?

ការរួមភេទដោយមិនប្រើស្រោមអនាម័យ

ការរួមភេទដោយមិនប្រើថ្នាំ PrEP (ថ្នាំបង្ការមេរោគអេដស៍)

ការប្រើប្រាស់ម្ជុល ឬ សឺរាំងចាក់ថ្នាំរួមគ្នា

ពីម្តាយទៅកូនក្នុងអំឡុងពេលមានផ្ទៃពោះ ពេលសម្រាល ឬ ពេលបំបៅដោះកូន



ការបញ្ចូលឈាមឈាមដែលមានមេរោគ (កម្រណាស់នាពេលបច្ចុប្បន្ននេះ)

មេរោគអេដស៍មិនរីករាលដាលតាមរយៈ:

ការឱប ឬថើប

ការទទួលទានអាហារ ឬភេសជ្ជៈរួមគ្នា

ការប្រើប្រាស់បង្គន់សាធារណៈ

មូសខាំ ឡើយ។

តើអ្វីខ្លះជារោគសញ្ញានៃមេរោគអេដស៍?

ពីដំបូង អ្នកអាចនឹងមានរោគសញ្ញាដែលអាចមើលទៅដូចជាជំងឺផ្តាសាយធំ ឬមេរោគផ្សេងទៀត។ រោគសញ្ញាដំបូងជាទូទៅរួមមាន៖

ឈឺក្បាល

អស់កម្លាំងខ្លាំង

ឈឺសាច់ដុំឬសន្លាក់

ឈឺបំពង់ក

ហើមក្រពេញ

ក្រុនក្តៅ

កន្ទួលក្រហម

ដំបៅក្រពះ

ការសម្រកទម្ងន់ដោយមិននឹកស្មានដល់។

ដឹងពីស្ថានភាពរបស់អ្នក - ធ្វើតេស្ត

មានការធ្វើតេស្តរកមេរោគអេដស៍ដោយសម្ងាត់នៅរដ្ឋ Rhode Island។

ការស្វែងរកស្ថានភាពមេរោគអេដស៍របស់អ្នកឱ្យបានទាន់ពេលវេលាគឺជួយសង្គ្រោះជីវិតមនុស្ស។

ការព្យាបាលជួយអ្នកផ្តុំកមេរោគអេដស៍ឱ្យមានអាយុវែង និងមានសុខភាពល្អ។

តើអ្វីទៅជាការធ្វើតេស្តរកមេរោគអេដស៍?

ការធ្វើតេស្តរកមេរោគអេដស៍ គឺពិនិត្យសំណាកឈាម ទឹកមាត់ (ទឹកមាត់ស្ពោះ) ឬទឹកនោម (នោម) ដើម្បីមើលឱ្យដឹងថាតើអ្នកឆ្លងមេរោគអេដស៍ដែរឬអត់។

តើអ្នកណាគួរធ្វើតេស្តរកមេរោគអេដស៍?

មនុស្សគ្រប់រូបដែលមានអាយុពី 13 ទៅ 64 ឆ្នាំគួរតែធ្វើតេស្តរកមេរោគអេដស៍យ៉ាងហោចណាស់ម្តង។ អ្នកដែលមានកត្តាហានិភ័យមួយចំនួនគួរតែធ្វើតេស្តឱ្យបានញឹកញាប់ជាងមុន។ ពិភាក្សាជាមួយគ្រូពេទ្យ ឬអ្នកជំនាញថែទាំសុខភាពអំពីថាតើអ្នកគួរធ្វើតេស្តញឹកញាប់ប៉ុណ្ណា។

ហេតុអ្វីខ្ញុំគួរតែធ្វើតេស្តរកមេរោគអេដស៍?

មធ្យោបាយតែមួយគត់ដើម្បីដឹងពីស្ថានភាពមេរោគអេដស៍របស់អ្នកគឺត្រូវធ្វើតេស្ត។ ប្រសិនបើការធ្វើតេស្តរបស់អ្នកវិជ្ជមាន អ្នកអាចប្រើថ្នាំដើម្បីព្យាបាលមេរោគអេដស៍ ដើម្បីជួយអ្នកឱ្យមានអាយុវែង មានសុខភាពល្អ និងការពារអ្នកដទៃ។ ប្រសិនបើលទ្ធផលតេស្តរបស់អ្នកអវិជ្ជមាន អ្នកអាចចាត់វិធានការដើម្បីការពារមេរោគអេដស៍។

របៀបធ្វើតេស្ត

- កន្លែងធ្វើតេស្តនឹងធានាការសម្ងាត់របស់អ្នក មុនពេលយកសំណាកឈាម។
- ការធ្វើតេស្តរហ័សអាចត្រូវបានធ្វើឡើងដោយប្រើតែសំណាកឈាមម្រាមដៃប៉ុណ្ណោះ។ ចំណាយពេលត្រឹមតែ 20 នាទីប៉ុណ្ណោះ។
- ឧបករណ៍ធ្វើតេស្តរហ័សត្រូវបានប្រើជាឧបករណ៍ពិនិត្យ។ ប្រសិនបើឧបករណ៍ធ្វើតេស្តរហ័សបង្ហាញលទ្ធផលវិជ្ជមាន អ្នកត្រូវធ្វើតេស្តឈាមដើម្បីបញ្ជាក់លទ្ធផលនោះ។

ថ្លៃចំណាយ

ការធ្វើតេស្តរកមេរោគអេដស៍ត្រូវបានបង់ថ្លៃដោយធានារ៉ាប់រងសុខភាពភាគច្រើន។ កន្លែងធ្វើតេស្តជាច្រើនក៏មានធ្វើតេស្តដោយមិនគិតថ្លៃ ឬដោយគិតថ្លៃតិចតួចផងដែរ។ សូមឆែកជាមួយកន្លែងនោះដើម្បីដឹងព័ត៌មានបន្ថែម។

កន្លែងដែលត្រូវទទួលការធ្វើតេស្ត

- ស្វែងរកអ្នកជំនាញថែទាំបឋម ឬគ្លីនិកដែលនៅជិតអ្នក។
- សូមពិនិត្យមើលកម្មវិធីធ្វើតេស្ត 1-2-3 របស់ក្រសួងសុខាភិបាលរដ្ឋ Rhode Island (testing123ri.com) ដើម្បីជួយក្នុងការធ្វើតេស្តរកមេរោគអេដស៍ ជំងឺរលាកថ្លើមប្រភេទ C និងជំងឺកាមរោគ។
- ទទួលបានការធ្វើតេស្តរកមេរោគអេដស៍យ៉ាងឆាប់រហ័ស ជាសម្ងាត់ និងដោយឥតគិតថ្លៃពីអង្គការសហគមន៍ជាច្រើននៅទូទាំងរដ្ឋ Rhode Island។
- បញ្ជាទិញឧបករណ៍ធ្វើតេស្តរកមេរោគអេដស៍នៅផ្ទះដោយឥតគិតថ្លៃពីគម្រោង AIDS Project RI។

ដើម្បីស្វែងយល់បន្ថែមអំពីជម្រើសធ្វើតេស្ត ឬទទួលបានជំនួយក្នុងការស្វែងរកការថែទាំ ឬស្រោមអនាម័យ សូមចូលទៅកាន់ health.ri.gov/youroptions ឬឆែកមើលក្នុង RIghtToKnow app។ អ្នកក៏អាច ទូរសព្ទទៅក្រសួងសុខាភិបាលរដ្ឋ Rhode Island តាមរយៈលេខ 401-222-5960 បានដែរ។

ឯកជនភាព

អាស្រ័យលើកន្លែងដែលអ្នកទទួលការធ្វើតេស្ត ការធ្វើតេស្តរកមេរោគអេដស៍គឺជាលក្ខណៈអនាមិក ឬជាសម្ងាត់។ ប្រភេទទាំងពីរនេះ រក្សាកម្រិតឯកជនភាពបានខ្ពស់បំផុត។

ការបង្ការគឺជាថ្នាមពល

- ប្រើប្រាស់ស្រោមអនាម័យឱ្យបានត្រឹមត្រូវគ្រប់ពេលវេលា។
- ធ្វើតេស្តឱ្យបានទៀងទាត់។ ស្វែងយល់បន្ថែមអំពីអ្នកណាខ្លះដែលគួរធ្វើតេស្តតាមតំណ health.ri.gov/hiv/hiv-testing
- ប្រើថ្នាំ PrEP (លេប ឬចាក់ ដែលកាត់បន្ថយឱកាសឆ្លងមេរោគអេដស៍) ប្រសិនបើមានហានិភ័យ។ ស្វែងយល់បន្ថែមតាមតំណ health.ri.gov/prep។
- កុំប្រើម្ជុលរួមគ្នា។

វាមានសារៈសំខាន់ក្នុងការទទួលការថែទាំដែលអ្នកត្រូវការដើម្បីឱ្យមានសុខភាពល្អ។ ប្រសិនបើអ្នកមានសំណួរផ្លូវច្បាប់ទាក់ទងនឹងសិទ្ធិអន្តោប្រវេសន៍ក្នុងការចូលប្រើសេវាថែទាំសុខភាពដោយសម្ងាត់ សូមទូរសព្ទទៅ Dorcas International តាមរយៈលេខ **401-784-8607**.

RHODE ISLAND DEPARTMENT OF HEALTH

DORCAS INTERNATIONAL
INSTITUTE OF RHODE ISLAND